**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ: ០១៤/២២**

# កិច្ចសន្យា
## ស្តីពីការជួសជុលបណ្តាញអគ្គីសនីក្នុង និងក្រៅអគារ
## រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

កិច្ចសន្យានេះធ្វើឡើងរវាង៖

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដោយលោក ជៀវ វីន មុខងារប្រធាននាយកដ្ឋានស្តង់ដារ និង សុវត្ថិភាពអាកាសយានដ្ឋាន មានអាសយដ្ឋានអគារលេខៈ ៤៤,មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន,សង្កាត់ កាកាប,ខណ្ឌ ពោធិ៍សែនជ័យ,រាជធានីភ្នំពេញ ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" និង

-ក្រុមហ៊ុន មិនា អ៊ិនវេសម៉ិន តំណាងដោយ លោក កែវ សុមិនា មុខងារ ប្រធានក្រុមហ៊ុន មិនា អ៊ិនវេសម៉ិន ដែលចាប់ពីពេលនេះតទៅហៅថា "អ្នកទទួលការ" មានអាសយដ្ឋានលេខៈ ៥៦F , ផ្លូវលេខ ៣៤៨ ,សង្កាត់ ទួលស្វាយព្រៃទី១,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ លេខទូរស័ព្ទៈ ០១២ ៨៩៤ ១៧៤ អ៊ីមែល.............. ..................................................... ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោម៖

**ប្រការ១- វិសាលភាពការងារ និងតម្លៃកិច្ចសន្យា**

"អ្នកម្ចាស់ការ" និង "អ្នកទទួលការ" យល់ព្រមប្រគល់-ទទួល អនុវត្តការងារជួសជុលបណ្តាញអគ្គីសនីក្នុង និងក្រៅអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលហៅកាត់ថា "ការងារ" ដែលមានតម្លៃទឹកប្រាក់សរុបចំនួនៈ៣៤១.៦៥៥.០០០រៀល(បីរយសែសិបមួយលាន ប្រាំមួយរយហាសិបប្រាំពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា។

**ប្រការ២- កាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់ "ការងារ"**

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន និងត្រូវបញ្ចប់ក្នុងរយៈពេល ៤២ថ្ងៃ (សែសិបពីរថ្ងៃ) ស្របតាមប្រតិទិនការងារដែលបានស្នើឡើងដោយ "អ្នកទទួលការ" ហើយត្រូវបានយល់ព្រមដោយ "អ្នកម្ចាស់ការ"។

**ប្រការ៣- ឯកសារឧបសម្ព័ន្ធ នៃកិច្ចសន្យា**

- លិខិតសម្រេច ប្រគល់កិច្ចសន្យា
- បញ្ជីប៉ាន់តម្លៃ( សរុប-ពលកម្ម-សម្ភារៈ )
- លម្អិតលក្ខណៈបច្ចេកទេស

- គំនូសប្លង់ និងប្រតិទិនការងារ
- លក្ខខណ្ឌ នៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត។

**ប្រការ៤- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

ភាគី "អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងចំនួនៈ ៣៤.១៦៥.៥០០រៀល (សាមសិបបួនលាន មួយរយហុកសិបប្រាំពាន់ប្រាំរយរៀលគត់) ក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬ រតនាគារ រាជធានី ខេត្ត បើកនៅធនាគារជាតិ នៃកម្ពុជា ឬសាខាធនាគារជាតិ រាជធានី ខេត្ត ឬកក់នៅ ធនាគារពាណិជ្ជ ដែល មានអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមមានៈ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២.ធនាគារ កាណាឌីយ៉ា ក.អ ,៣.ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា,៤.ធនាគារ កម្ពុជា សាធារណៈ ភីអិលស៊ី,៥.ធនាគារ វឌ្ឍនៈ ៦.ធនាគារ វឌ្ឍនៈអាស៊ីចំកាត់(ABA),៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី(CIMB),៨.ធនាគារ មេយ បែង (ខេមបូឌា)ភីអិលស៊ី, ៩.ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់,និង ១០.ធនាគារ ជីប ម៉ុង ខមមើសល បែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកទទួលការ" ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

**ប្រការ៥- ការចុះកិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឲ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឲ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ" ។ ក្នុងករណីដែល "អ្នកម្ចាស់ការ" យល់ព្រម ចំពោះការចុះកិច្ចសន្យាបន្ត ការយល់ព្រមនោះក៏មិនអាចបន្ធូរបន្ថយកាតព្វកិច្ចរបស់ "អ្នកទទួលការ" ដែលមានចែងក្នុងកិច្ចសន្យាដើមឡើយ។

**ប្រការ៦- ការគោរពបទដ្ឋានបច្ចេកទេសសំណង់**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត កម្ពស់ ទំហំ

ខ្នាត... ជាដើម ។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឲ្យបានសមស្រប មុននឹងធ្វើការប្រគល់-ទទួលសំណង់។

**ប្រការ៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា"អ្នកទទួលការ"ត្រូវអនុញ្ញាតឱ្យ "អ្នកម្ចាស់ការ" ចូលការដ្ឋានដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត។

**ប្រការ៨- ការបញ្ជាកែប្រែ**

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ។ ការកែប្រែនេះអាចមាន ៖

-ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា

-ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារៈអ្វីមួយទៅក្នុង "ការងារ"

-ការកែប្រែទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"

-ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ

-ការសាងសង់បន្ថែមណាមួយ

-ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ"។

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល។

**ប្រការ៩- ការពន្យារពេលបញ្ចប់ "ការងារ"**

"អ្នកទទួលការ"អាចស្នើសុំពន្យារពេលបញ្ចប់"ការងារ"បានដោយមានការយល់ព្រមពី"អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលបញ្ចប់ការងារមិនឲ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ" ។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។

**ប្រការ១០- ការសំអាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់ "ការងារ" ។"អ្នកទទួលការ"ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ"។

**ប្រការ១១- ការបញ្ចប់ការងារ**

"ការងារ"ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់-ទទួល

សំណង់ ។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំលិខិតបញ្ជាក់ស្ដីពីការបញ្ចប់ការងារពី "អ្នកម្ចាស់ការ" ។ "អ្នកម្ចាស់ការ" ត្រូវចេញលិខិតបញ្ជាក់ស្ដីពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន (១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់ "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

**ប្រការ១២- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល០៣ខែ(បីខែ) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ក្នុងករណីពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតីបណ្ដាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ ។ ការចំណាយលើការសាងសង់/ជួសជុលខាងលើជាបន្ទុករបស់"អ្នកទទួលការ"ទាំងស្រុង ។ ប្រសិនបើក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ "អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ"អ្នកទទួលការ"ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។ ករណីពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.. បណ្ដាលមកពីប្រធានស័ក្ដិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ"។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់-ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៣- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្ដាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុ គ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេលដប់(១០)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស។

**ប្រការ១៤- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់ គឺជាប្រាក់រៀល ។ ការទូទាត់តម្លៃកិច្ចសន្យា ត្រូវធ្វើតាមរយៈ អគ្គនាយកដ្ឋានរតនាគារជាតិ ដោយបង្វែរចូលគណនីរបស់ ភាគី"ខ" លេខ: ០៤៥០០០០០៤៨៦៨៨ នៅធនាគារ កាណាឌីយ៉ា ក.អ ។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តជាក់ ខាតបានត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ ហេតុត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃ និងប្រគល់-ទទួលសំណង់ (ព្រមទាំង មានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ ការទូទាត់ត្រូវធ្វើឡើងតែមួយលើកដោយអនុវត្ត ជាជំហានៗរយៈពេល ៤៥ថ្ងៃ(នៃថ្ងៃធ្វើការ)។

**ប្រការ១៥- ពន្ធ អាករ**

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយ អគ្គនាយកដ្ឋានរតនាគារជាតិ នាពេលទូទាត់តម្លៃកិច្ចសន្យា។

**ប្រការ១៦- ការផាកពិន័យ**

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្តាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ០,១០% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃ ដែលយឺតយ៉ាវ ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១០% នៃតម្លៃ កិច្ចសន្យា ។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១០% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ឈប់ កិច្ចសន្យា។

ក្នុងករណីដែលភាគី"អ្នកម្ចាស់ការ"និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវ នោះ។

**ប្រការ ១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណា មួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និង ភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែង ក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគី ទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នក ម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹង ត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការ តែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃ ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៨- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "អ្នកម្ចាស់ការ" នោះ ភាគី "អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

**ប្រការ១៩- ឱសានវាទ**

ភាគីទាំងពីរមានការកិច្ចអនុវត្តតាមកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់ ។ កិច្ចសន្យានេះត្រូវធ្វើជាភាសាខ្មែរ ចំនួន ប្រាំបី(០៨)ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

| | |
|---|---|
| - ភាគី "អ្នកម្ចាស់ការ" | ចំនួន ០៣ ច្បាប់ |
| - ភាគី "អ្នកទទួលការ" | ចំនួន ០៣ ច្បាប់ |
| - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ០១ ច្បាប់ |
| - ឯកសារ-កាលប្បវត្តិ | ចំនួន ០១ ច្បាប់ |

ថ្ងៃ.....................ខែ...............ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី...២៨...ខែ...កក្កដា...ឆ្នាំ ២០២២

**ភាគី "អ្នកម្ចាស់ការ"**

ជៀច_វីន

ប្រធាននាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន

**ភាគី "អ្នកទទួលការ"**

កែវ_សុមិនា

**បានឃើញ និង ឯកភាព**

ថ្ងៃ.....................ខែ...............ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី...២៨...ខែ...កក្កដា...ឆ្នាំ ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខៈ ០១២/២២**

# កិច្ចសន្យា
## ស្តីពីការបោះបង្គោលព្រំខណ្ឌដី នៅអាកាសយានដ្ឋានមណ្ឌលគិរី

កិច្ចសន្យានេះធ្វើឡើងរវាងៈ

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដោយលោក ជៀវ វីន មុខងារប្រធាននាយកដ្ឋានស្តង់ដារ និងសុវត្ថិភាពអាកាសយានដ្ឋាន មានអាសយដ្ឋានអគារលេខៈ ៤៤,មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន,សង្កាត់កាកាប,ខណ្ឌ ពោធិ៍សែនជ័យ,រាជធានីភ្នំពេញ ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" និង

-ក្រុមហ៊ុន មិនា អ៊ិនវេសមិន តំណាងដោយ លោក កែវ សុមិនា មុខងារ ប្រធានក្រុមហ៊ុន មិនា អ៊ិនវេសមិន ដែលចាប់ពីពេលនេះតទៅហៅថា "អ្នកទទួលការ" មានអាសយដ្ឋានលេខៈ ៥៦F , ផ្លូវលេខ ៣៤៨ ,សង្កាត់ទួលស្វាយព្រៃទី១,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ លេខទូរស័ព្ទៈ ០១២ ៨៩៤ ១៧៤ អ៊ីមែល...........។

ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោមៈ

**ប្រការ១- វិសាលភាពការងារ និងតម្លៃកិច្ចសន្យា**

"អ្នកម្ចាស់ការ" និង "អ្នកទទួលការ" យល់ព្រមប្រគល់-ទទួល អនុវត្តការងារបោះបង្គោលព្រំខណ្ឌដីនៅអាកាសយានដ្ឋានមណ្ឌលគិរី ដែលហៅកាត់ថា "ការងារ" ដែលមានតម្លៃទឹកប្រាក់សរុបចំនួនៈ ១៤១.៩១០.០០០រៀល (មួយរយសែសិបមួយលាន ប្រាំបួនរយដប់ពាន់រៀលគត់)ជាតម្លៃកិច្ចសន្យា។

**ប្រការ២- កាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់ "ការងារ"**

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន និងត្រូវបញ្ចប់ក្នុងរយៈពេល ៧០ថ្ងៃ (ចិតសិបថ្ងៃ) ស្របតាមប្រតិទិនការងារដែលបានស្នើឡើងដោយ "អ្នកទទួលការ" ហើយត្រូវបានយល់ព្រមដោយ "អ្នកម្ចាស់ការ"។

**ប្រការ៣- ឯកសារឧបសម្ព័ន្ធ នៃកិច្ចសន្យា**

- លិខិតសម្រេច ប្រគល់កិច្ចសន្យា
- បញ្ជីប៉ាន់តម្លៃ( សរុប-ពលកម្ម-សម្ភារៈ)
- លម្អិតលក្ខណៈបច្ចេកទេស
- គំនូសប្លង់ និងប្រតិទិនការងារ
- លក្ខខណ្ឌ នៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត។

**ប្រការ៤- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

ភាគី "អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងចំនួនៈ ១៤.១៩១.០០០រៀល (ដប់បួនលាន មួយរយកៅសិបមួយពាន់រៀលគត់) នៅក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬ រតនាគារ រាជធានី ខេត្ត បើកនៅធនាគារជាតិ នៃកម្ពុជា ឬសាខាធនាគារជាតិ រាជធានី ខេត្ត ឬកក់នៅ ធនាគារពាណិជ្ជ ដែលមានអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមមានៈ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២.ធនាគារ កាណាឌីយ៉ា ក.អ,៣.ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា,៤.ធនាគារ កម្ពុជា សាធារណៈ ភីអិលស៊ី,៥.ធនាគារ វឌ្ឍនៈ,៦.ធនាគារ វឌ្ឍនៈអាស៊ីចំកាត់(ABA),៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី(CIMB),៨.ធនាគារ មេយ បែង (ខេមបូឌា)ភីអិលស៊ី,៩.ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់,និង១០.ធនាគារ ជីប ម៉ុង ខមមើសល បែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកទទួលការ" ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា(មានទម្រង់និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិកាជាតិ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

**ប្រការ៥- ការចុះកិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឲ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឲ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ" ។ ក្នុងករណីដែល "អ្នកម្ចាស់ការ" យល់ព្រម ចំពោះការចុះកិច្ចសន្យាបន្ត ការយល់ព្រមនោះក៏មិនអាចបន្ធូរបន្ថយកាតព្វកិច្ចរបស់ "អ្នកទទួលការ" ដែលមានចែងក្នុងកិច្ចសន្យាដើមឡើយ។

**ប្រការ៦- ការគោរពបទដ្ឋានបច្ចេកទេសសំណង់**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត កម្ពស់ ទំហំ ខ្នាត... ជាដើម ។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឲ្យបានសមស្រប មុននឹងធ្វើការប្រគល់-ទទួលសំណង់។

**ប្រការ៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា"អ្នកទទួលការ"ត្រូវអនុញ្ញាតឱ្យ "អ្នកម្ចាស់ការ" ចូលការដ្ឋាន ដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត។

**ប្រការ៨- ការបញ្ជាកែប្រែ**

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ។ ការកែប្រែនេះអាចមាន ៖

-ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា

-ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារៈអ្វីមួយទៅក្នុង "ការងារ"

-ការកែប្រែទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"

-ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ

-ការសាងសង់បន្ថែមណាមួយ

-ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ"។

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល។

**ប្រការ៩- ការពន្យារពេលបញ្ចប់ "ការងារ"**

"អ្នកទទួលការ" អាចស្នើសុំពន្យារពេលបញ្ចប់ "ការងារ" បានដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលបញ្ចប់ការងារមិនឲ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ" ។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។

**ប្រការ១០- ការសំអាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់ "ការងារ" ។ "អ្នកទទួលការ" ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ"។

**ប្រការ១១- ការបញ្ចប់ការងារ**

"ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់-ទទួលសំណង់ ។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារពី"អ្នកម្ចាស់ការ" ។ "អ្នកម្ចាស់ការ" ត្រូវចេញលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន

(១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់ "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

**ប្រការ១២- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល០៣ខែ(បីខែ) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ក្នុងករណីពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតី បណ្ដាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ ។ ការចំណាយលើការសាងសង់/ជួសជុលខាងលើជាបន្ទុករបស់"អ្នកទទួលការ"ទាំងស្រុង ។ ប្រសិនបើក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ"អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ"អ្នកទទួលការ"ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។ ករណីពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ...... បណ្ដាលមកពីប្រធានស័ក្តិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ"។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់-ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៣- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្ដាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុ គ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេលដប់(១០)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស។

**ប្រការ១៤- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់ គឺជាប្រាក់រៀល ។ ការទូទាត់តម្លៃកិច្ចសន្យា ត្រូវធ្វើតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយបង្វែរចូលគណនីរបស់ ភាគី"ខ" លេខ: ០៤៥០០០០០៤៨៦៨៨ នៅធនាគារ កាណាឌីយ៉ា ក.អ។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តដាច់ខាតបានត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ហេតុត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃ និងប្រគល់-ទទួលសំណង់ (ព្រមទាំងមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ ការទូទាត់ត្រូវធ្វើឡើងតែមួយលើកដោយអនុវត្តជាជំហានៗរយៈពេល ៤៥ថ្ងៃ(នៃថ្ងៃធ្វើការ)។

**ប្រការ១៥- ពន្ធ អាករ**

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ នាពេលទូទាត់តម្លៃកិច្ចសន្យា។

**ប្រការ១៦- ការផាកពិន័យ**

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្ដាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ០,១០% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃដែលយឺតយ៉ាវ ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១០% នៃតម្លៃកិច្ចសន្យា ។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១០% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ឈប់កិច្ចសន្យា។

ក្នុងករណីដែលភាគី"អ្នកម្ចាស់ការ"និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។

**ប្រការ ១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និង ភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នកម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្ដាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្ដាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៨- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "អ្នកម្ចាស់ការ" នោះ ភាគី "អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

**ប្រការ១៩- ឱសានវាទ**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់ ។ កិច្ចសន្យានេះត្រូវធ្វើជាភាសាខ្មែរ ចំនួន ប្រាំបី(០៨)ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

| | |
|---|---|
| - ភាគី "អ្នកម្ចាស់ការ" | ចំនួន ០៣ ច្បាប់ |
| - ភាគី "អ្នកទទួលការ" | ចំនួន ០៣ ច្បាប់ |
| - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ០១ ច្បាប់ |
| - ឯកសារ-កាលប្បវត្តិ | ចំនួន ០១ ច្បាប់ |

ថ្ងៃ...ព្រហស្បតិ៍ ១៥កើត...ខែ...ពិសាខ...ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី...២៨...ខែ...កក្កដា...ឆ្នាំ ២០២២

**ភាគី "អ្នកម្ចាស់ការ"**

ជៀវ_វីន

ប្រធាននាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន

**ភាគី "អ្នកទទួលការ"**

MINEA INVESTMENT Co., Ltd

KINGDOM OF CAMBODIA

កែវ_សុមិនា

**បានឃើញ និង ឯកភាព**

ថ្ងៃ...ព្រហស្បតិ៍ ១៥កើត...ខែ...ពិសាខ...ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី...២៨...ខែ...កក្កដា...ឆ្នាំ ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

A2

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខៈ ០១៣/២២**

# កិច្ចសន្យា
# ស្តីពីការសាងសង់រោងចំណតរថយន្ត និងម៉ូតូ
# នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល

កិច្ចសន្យានេះធ្វើឡើងរវាង៖

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដោយលោក ជៀវ វីន មុខងារប្រធាននាយកដ្ឋានស្តង់ដារ និងសុវត្ថិភាពអាកាសយានដ្ឋាន មានអាសយដ្ឋានអគារលេខៈ ៤៤,មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន,សង្កាត់កាកាប,ខណ្ឌ ពោធិ៍សែនជ័យ,រាជធានីភ្នំពេញ ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" និង

-ក្រុមហ៊ុន មិនា អ៊ិនវេសម៉ិន តំណាងដោយ លោក កែវ សុមិនា មុខងារ ប្រធានក្រុមហ៊ុន មិនា អ៊ិនវេសម៉ិន ដែលចាប់ពីពេលនេះតទៅហៅថា "អ្នកទទួលការ" មានអាសយដ្ឋានលេខៈ ៥៦F , ផ្លូវលេខ ៣៤៨ ,សង្កាត់ទួលស្វាយព្រៃទី១,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ លេខទូរស័ព្ទៈ ០១២ ៨៩៤ ១៧៤ អ៊ីមែល...........។

ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោម៖

**ប្រការ១- វិសាលភាពការងារ និងតម្លៃកិច្ចសន្យា**

"អ្នកម្ចាស់ការ" និង "អ្នកទទួលការ" យល់ព្រមប្រគល់-ទទួល អនុវត្តការងារសាងសង់រោងចំណតរថយន្ត និងម៉ូតូ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ដែលហៅកាត់ថា "ការងារ" ដែលមានតម្លៃទឹកប្រាក់សរុបចំនួនៈ ២៤៣.៣៩៥.៣០០រៀល (ពីររយសែសិបបីលាន បីរយកៅសិបប្រាំពាន់បីរយរៀលគត់) ជាតម្លៃកិច្ចសន្យា។

**ប្រការ២- កាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់ "ការងារ"**

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន និងត្រូវបញ្ចប់ក្នុងរយៈពេល ៥៦ថ្ងៃ (ហាសិបប្រាំមួយថ្ងៃ) ស្របតាមប្រតិទិនការងារដែលបានស្នើឡើងដោយ "អ្នកទទួលការ" ហើយត្រូវបានយល់ព្រមដោយ "អ្នកម្ចាស់ការ"។

**ប្រការ៣- ឯកសារឧបសម្ព័ន្ធ នៃកិច្ចសន្យា**

- លិខិតសម្រេច ប្រគល់កិច្ចសន្យា
- បញ្ជីប៉ាន់តម្លៃ(សរុប-ពលកម្ម-សម្ភារៈ)
- លម្អិតលក្ខណៈបច្ចេកទេស
- គំនូសប្លង់ និងប្រតិទិនការងារ

- លក្ខខណ្ឌ នៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត។

**ប្រការ៤- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

ភាគី "អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹង ចំនួនៈ ២៤.៣៣៩.៦០០រៀល (ម្ភៃបួនលាន បីរយសាមសិបប្រាំបួនពាន់ប្រាំមួយរយរៀលគត់) ក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិឬរតនាគាររាជធានីខេត្តបើកនៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិរាជធានីខេត្ត ឬកក់នៅធនាគារពាណិជ្ជ ដែលមានអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន៖ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២.ធនាគារ កាណាឌីយ៉ា ក.អ , ៣.ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា,៤.ធនាគារ កម្ពុជា សាធារណៈ ភីអិលស៊ី, ៥.ធនាគារ វឌ្ឍនៈ, ៦.ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA), ៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី(CIMB) ,៨.ធនាគារ មេយ ប៊ែង(ខេមបូឌា)ភីអិលស៊ី ,៩.ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់,និង ១០.ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកទទួលការ"ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា(មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

**ប្រការ៥- ការចុះកិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្ត នៃកិច្ចសន្យាទាំងមូល មិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឲ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឲ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ" ។ ក្នុងករណីដែល "អ្នកម្ចាស់ការ" យល់ព្រម ចំពោះការចុះកិច្ចសន្យាបន្ត ការយល់ព្រមនោះក៏មិនអាចបន្ធូរបន្ថយកាតព្វកិច្ចរបស់ "អ្នកទទួលការ" ដែលមានចែងក្នុងកិច្ចសន្យាដើមឡើយ។

**ប្រការ៦- ការគោរពបទដ្ឋានបច្ចេកទេសសំណង់**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត កម្ពស់ ទំហំ

ខ្នាត... ជាដើម ។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឲ្យបានសមស្រប មុននឹងធ្វើការប្រគល់-ទទួលសំណង់។

**ប្រការ៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា"អ្នកទទួលការ"ត្រូវអនុញ្ញាតឱ្យ "អ្នកម្ចាស់ការ" ចូលការដ្ឋានដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត។

**ប្រការ៨- ការបញ្ជាកែប្រែ**

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ។ ការកែប្រែនេះអាចមាន ៖

-ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា

-ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារៈអ្វីមួយទៅក្នុង "ការងារ"

-ការកែប្រែទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"

-ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ

-ការសាងសង់បន្ថែមណាមួយ

-ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ"។

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល។

**ប្រការ៩- ការពន្យារពេលបញ្ចប់ "ការងារ"**

"អ្នកទទួលការ"អាចស្នើសុំពន្យារពេលបញ្ចប់"ការងារ"បានដោយមានការយល់ព្រមពី"អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលបញ្ចប់ការងារមិនឲ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ" ។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។

**ប្រការ១០- ការសំអាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់ "ការងារ" ។ "អ្នកទទួលការ" ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ"។

**ប្រការ១១- ការបញ្ចប់ការងារ**

"ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់-

ទទួលសំណង់ ។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារពី"អ្នកម្ចាស់ការ" ។ "អ្នកម្ចាស់ការ" ត្រូវចេញលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន (១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់ "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

**ប្រការ១២- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល០៣ខែ(បីខែ) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ក្នុងករណីពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតី បណ្តាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ ។ ការចំណាយលើការសាងសង់/ជួសជុលខាងលើជាបន្ទុករបស់"អ្នកទទួលការ"ទាំងស្រុង ។ ប្រសិនបើក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ"អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ"អ្នកទទួលការ"ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។ ករណីពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ...... បណ្តាលមកពីប្រធានស័ក្តិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ"។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់-ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៣- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្តាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុ គ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេលដប់(១០)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស។

**ប្រការ១៤- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់ គឺជាប្រាក់រៀល ។ ការទូទាត់តម្លៃកិច្ចសន្យា ត្រូវធ្វើតាមរយៈ អគ្គនាយកដ្ឋានរតនាគារជាតិ ដោយបង្វែរចូលគណនីរបស់ ភាគី"ខ" លេខ: ០៩៥០០០០០៤៨៦៨៨ នៅធនាគារ កាណាឌីយ៉ា ក.អ ។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តជាប់ ខាតបានត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ ហេតុត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃ និងប្រគល់-ទទួលសំណង់ (ព្រមទាំង មានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ ការទូទាត់ត្រូវធ្វើឡើងតែមួយលើកដោយអនុវត្ត ជាជំហានៗរយៈពេល ៤៥ថ្ងៃ(នៃថ្ងៃធ្វើការ)។

**ប្រការ១៥- ពន្ធ អាករ**

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយ អគ្គនាយកដ្ឋានរតនាគារជាតិ នាពេលទូទាត់តម្លៃកិច្ចសន្យា។

**ប្រការ១៦- ការផាកពិន័យ**

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្តាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ០,១០% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃ ដែលយឺតយ៉ាវ ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១០% នៃតម្លៃ កិច្ចសន្យា ។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១០% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ឈប់ កិច្ចសន្យា។

ក្នុងករណីដែលភាគី"អ្នកម្ចាស់ការ"និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវ នោះ។

**ប្រការ ១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណា មួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និង ភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែង ក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគី ទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នក ម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹង ត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការ តែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃ ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៨- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "អ្នកម្ចាស់ការ" នោះ ភាគី "អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

**ប្រការ១៩- និគមនវាចា**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់ ។ កិច្ចសន្យានេះត្រូវធ្វើជាភាសាខ្មែរ ចំនួន ប្រាំបី(០៨)ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

- ភាគី "អ្នកម្ចាស់ការ" ចំនួន ០៣ ច្បាប់
- ភាគី "អ្នកទទួលការ" ចំនួន ០៣ ច្បាប់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) ចំនួន ០១ ច្បាប់
- ឯកសារ-កាលប្បវត្តិ ចំនួន ០១ ច្បាប់

ថ្ងៃ.................ខែ...អាសាឍ....ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី.........ខែ...កក្កដា....ឆ្នាំ ២០២២

**ភាគី "អ្នកម្ចាស់ការ"**

ឡៅ ទីន

ប្រធាននាយកដ្ឋានស្តង់ដានិងសុវត្ថិភាពការសាងសង់ផ្លូវ

**ភាគី "អ្នកទទួលការ"**

ក្រុមហ៊ុន មិនា អិនវេសមិន

MINEA INVESTMENT Co., Ltd

KINGDOM OF CAMBODIA

កែវ សុមិនា

**បានឃើញ និង ឯកភាព**

ថ្ងៃ.................ខែ...អាសាឍ....ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ...កក្កដា....ឆ្នាំ ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាចណ្ណាល់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខៈ ០០១/២២**

# កិច្ចសន្យា

## ស្តីពីការថែទាំ និងសម្អាតអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ប្រចាំឆ្នាំ ២០២២

កិច្ចសន្យានេះធ្វើឡើងរវាង៖

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដោយ **លោក ឈុន គីមឃាង** ជាអនុប្រធាននាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" ហៅកាត់ថា ភាគី "ក" មានអាសយដ្ឋានអគារលេខៈ ៤៤, មហាវិថីសហព័ន្ធរុស្សី, ភូមិតាងួន, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ ទូរស័ព្ទលេខៈ ០៧៧ ៨០៧ ៣៣៣ និង

-ក្រុមហ៊ុន **មិនា អ៊ិនវេសមិន** ត្រូវបានទទួលស្គាល់ថាជា "អ្នកទទួលការ" ហៅកាត់ថា ភាគី "ខ" តំណាងដោយ **លោក កែវ សុមិនា** មុខងារ ជាប្រធានក្រុមហ៊ុន **មិនា អ៊ិនវេសមិន** មានអាសយដ្ឋានផ្ទះលេខៈ ៥៦F, ផ្លូវលេខៈ ៣៤៨, សង្កាត់ទួលស្វាយព្រៃទី១, ខណ្ឌចំការមន, រាជធានីភ្នំពេញ, ទូរស័ព្ទលេខៈ ០១២ ៨៩៤ ១៧៤។

ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោម ៖

### ប្រការ ១- អំពីគោលការណ៍

ភាគីទាំងពីរបានព្រមព្រៀងប្រគល់-ទទួលការងារថែទាំ និងសម្អាតអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ប្រចាំឆ្នាំ ២០២២ ដែលមានទឹកប្រាក់សរុបចំនួនៈ ២៨៣.០០៨.០០០រៀល(ពីររយប៉ែតសិបបីលាន ប្រាំបីពាន់រៀលគត់)ជាតម្លៃកិច្ចសន្យា។

### ប្រការ ២- បរិយាយលក្ខណៈបច្ចេកទេស

ភាគី "ខ" បានយល់ព្រមទទួលការងារថែទាំ និងសម្អាតអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ប្រចាំឆ្នាំ ២០២២ ដែលមានបរិមាណ និងលក្ខណៈបច្ចេកទេសដូចមានចែងក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេសដូចតារាងខាងក្រោម៖

| ល.រ | បរិយាយ | បរិមាណ | តម្លៃក្នុង១ម$^2$(ជារៀល) | តម្លៃក្នុង១ខែ(ជារៀល) | តម្លៃក្នុង១ឆ្នាំ(ជារៀល) |
|---|---|---|---|---|---|
| ១ | សេវាថែទាំ និងសំអាតអគាររដ្ឋបាល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៦.៤៤៨ម$^2$ | ២.៩៤៨ | ១៩.០០៨.៧០៤ | ២២៨.១០៤.៤៤៨ |
| ២ | សេវាថែទាំ និងសំអាតអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល | ១.៥៥២ម$^2$ | ២.៩៤៨ | ៤.៥៧៥.២៩៦ | ៥៤.៩០៣.៥៥២ |
| ★ | សរុបរួម | | | | ២៨៣.០០៨.០០០ |

### ប្រការ ៣- ឯកសារខ្ទបសម្ព័ន្ធរបស់កិច្ចសន្យា

- លិខិតសម្រេចប្រគល់កិច្ចសន្យា

- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
- ប៉ាន់គំរូកាតាឡុក
- លក្ខខណ្ឌនៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត

**ប្រការ ៤- ការប្រគល់-ទទួល**

ភាគី "ខ" ត្រូវបញ្ចប់ការងារទាំងអស់ ជូនភាគី "ក" តាមទីតាំងដែលបានកំណត់ បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន។ ការប្រគល់-ទទួល ត្រូវពិនិត្យឱ្យបានហ្មត់ចត់ត្រឹមត្រូវតាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស ដូចមានចែងក្នុងតារាងតម្លៃ។

ការប្រគល់-ទទួល អាចធ្វើឡើង ដោយមានកំណត់ហេតុប្រគល់-ទទួល ច្បាស់លាស់របស់គណៈកម្មការប្រគល់-ទទួល ដោយមានការយល់ព្រមពីប្រធានគណៈកម្មាធិការលទ្ធកម្ម និងត្រូវមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥- ការធានាគុណភាពទំនិញ**

ភាគី "ខ" ត្រូវធានាថា រាល់គុណភាពទំនិញត្រូវឆ្លើយតបទៅនឹងប៉ាន់គំរូ កាតាឡុក និងធានាថាទំនិញដែលត្រូវប្រគល់ ជាទំនិញដែលមានលក្ខណៈបច្ចេកទេសស្របតាមលក្ខខណ្ឌដែលភាគី "ក" បានកំណត់។ ភាគី "ខ" យល់ព្រមផ្លាស់ប្តូរជំនួស ឬកែតម្រូវដោយចំណាយផ្ទាល់ខ្លួន ចំពោះមុខទំនិញដែលខូចខាត ឬផ្នែកណាមួយនៃទំនិញ ក្រោយពីភាគី "ក" បានប្រាប់ឱ្យដឹងអំពីលក្ខណៈនៃការខូចខាតនោះ។ ប្រសិនបើភាគី "ខ" ខកខានមិនបានសងការខូចខាត ឬជំនួសទេនោះ ភាគី "ក" អាចចាត់វិធានការចាំបាច់ទិញពីអ្នកផ្សេងទៀត ដែលការចំណាយជាបន្ទុករបស់ភាគី "ខ" ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិណាមួយរបស់ភាគី "ក" ដែលមាននៅក្នុងកិច្ចសន្យា។ ករណីមានការធានាលើសេវាប្រើប្រាស់ ត្រូវចែងឱ្យបានច្បាស់ក្នុងកិច្ចសន្យា។

**ប្រការ ៦- ប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា**

ភាគី "ខ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាដែលមានទឹកប្រាក់ស្មើនឹងចំនួនៈ ២៨.៣០០.៨០០រៀល ក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ រាជធានីខេត្ត បើកនៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ រាជធានីខេត្ត ឬកក់នៅធនាគារពាណិជ្ជ ដែលមានអនុស្សារណៈយោគយល់គ្នាជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមានៈ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២.ធនាគារ កាណាឌីយ៉ា ក.អ, ៣.ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា, ៤.ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី, ៥.ធនាគារ វឌ្ឍនៈ, ៦.ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់(ABA), ៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី(CIMB), ៨.ធនាគារ មេយ ប៊ែង(ខេមបូឌា)ភីអិលស៊ី, ៩.ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់, និង ១០.ធនាគារ ធីប ម៉ុង ខមមើសលប៊ែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច ភាគី "ខ" ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្ត (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូនភាគី "ក" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ប្រាក់កក់នេះត្រូវប្រគល់ជូនភាគី "ខ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលប្រគល់-ទទួលទំនិញ ចប់ជាស្ថាពរ ឬក្រោយពេលផុតរយៈពេលធានាគុណភាពទំនិញ។

ក្នុងករណីភាគី "ខ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តនេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

**ប្រការ ៧- ការកែប្រែបញ្ជាទិញ**

ប្រសិនបើ ភាគី "ក" មានបំណងផ្លាស់ប្តូរការបញ្ជាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគី "ខ" និងត្រូវប្រជុំដោះស្រាយការកែប្រែលើកិច្ចសន្យា។ ការកែប្រែ អាចធ្វើឡើងក្នុងលក្ខណៈបច្ចេកទេស បរិមាណ និងទីកន្លែងប្រគល់-ទទួល។

ប្រសិនបើភាគី "ខ" ទទួលយកនូវការកែប្រែនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងនោះ ការកែប្រែនឹងក្លាយទៅជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា។ ការកែប្រែត្រូវមានការឯកភាពជាចុងក្រោយពីប្រធានគណៈកម្មាធិការលទ្ធកម្ម និងត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៨- ការត្រួតពិនិត្យ និងការសាកពិសោធន៍**

ប្រសិនបើភាគី "ក" ត្រូវការត្រួតពិនិត្យលើគុណភាពទំនិញនោះភាគី "ខ" ត្រូវបង្កភាពងាយស្រួលក្នុងការផ្តល់គំរូ ទិន្នន័យនៃផលិតផល លិខិតជានាផ្សេងៗ កាតាឡុក ដើម្បីឱ្យដំណើរការសាកពិសោធន៍ ឬការត្រួតពិនិត្យប្រព្រឹត្តទៅបានឆាប់រហ័ស ដោយមិនគិតសោហ៊ុយចំណាយពីភាគី "ក" បន្ថែមទៀតទេ។ ប្រសិនបើទំនិញដែលបានត្រួតពិនិត្យ ឬសាកពិសោធន៍ឃើញថាមិនសមស្របតាមលក្ខណៈបច្ចេកទេសនោះ ភាគី "ក" អាចបដិសេធ ហើយភាគី "ខ" ចាំបាច់ត្រូវធ្វើការកែតម្រូវតាមលក្ខណៈបច្ចេកទេសដែលបានកំណត់ ហើយសោហ៊ុយចំណាយជាបន្ទុករបស់ភាគី "ខ"។

**ប្រការ ៩- ការពន្យារពេលផ្គត់ផ្គង់**

ភាគី "ខ" អាចស្នើសុំពន្យារពេលការងារ បានដោយមានការយល់ព្រមពីភាគី "ក" ផ្អែកលើមូលហេតុជាក់ស្តែង។ ភាគី "ខ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលការងារ មិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ភាគី "ខ"។ ប្រសិនបើភាគី "ខ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។ ការពន្យារពេលនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១០- ករណីប្រធានសក្តិ**

ក្នុងករណីប្រធានសក្តិ ដូចជាភ្លើងឆេះ ទឹកជំនន់ រញ្ជួយផែនដី ជម្ងឺរាលដាល បាតុកម្ម កុបកម្ម ទណ្ឌកម្មសេដ្ឋកិច្ច និងវិបត្តិភ័យដទៃទៀត ឬព្រឹត្តិការណ៍ដែលធ្វើឱ្យភាគី "ខ" មានការលំបាកខ្លាំងក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់ ភាគី "ខ" ត្រូវផ្តល់ព័ត៌មានជូន ភាគី "ក" ឱ្យបានឆាប់តាមតែអាចធ្វើបាន ដើម្បីស្វែងរកដំណោះស្រាយ។

ប្រសិនបើភាគី "ខ" មិនបានផ្តល់ព័ត៌មានទាន់ពេលវេលាទេនោះ ភាគី "ក" នឹងមិនទទួលខុសត្រូវចំពោះបញ្ហានេះឡើយ។

ការយឺតយ៉ាវ ឬការខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានសក្តិនេះ ភាគី "ខ" មិនត្រូវបានទទួលរងនូវការផាកពិន័យ ឬរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាឡើយ។

**ប្រការ ១១- កិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត។ ភាគី "ខ" អាចចុះកិច្ចសន្យាបន្តឱ្យ "អ្នកទទួលការបន្ត" ដើម្បីឱ្យអនុវត្តផ្នែកណាមួយ នៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពីភាគី "ក" ។ "អ្នកទទួលការបន្ត" ត្រូវចុះកិច្ចសន្យាជាមួយ ភាគី "ខ" មិនមែនចុះកិច្ចសន្យាជាមួយ ភាគី "ក" នោះទេ។ ប្រសិនបើ "អ្នកទទួលការបន្ត" មានកំហុសឆ្គងណាមួយ ភាគី "ខ" ត្រូវទទួលខុសត្រូវទាំងស្រុង ដោយធានាថាកំហុសទាំងនោះត្រូវបានកែតម្រូវ។ ភាគី "ក" មិនត្រូវធ្វើការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយ "អ្នកទទួលការបន្ត" ឡើយ។ ការចុះកិច្ចសន្យាបន្តត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១២- ការបញ្ចប់កិច្ចសន្យា**

ភាគី "ក" អាចពិចារណាលើការលុបកិច្ចសន្យាទាំងមូល ឬផ្នែកខ្លះតាមកាលៈទេសៈដូចខាងក្រោម៖

- ប្រសិនបើភាគី "ខ" មិនមានលទ្ធភាពប្រគល់នូវមុខការងារតាមកាលកំណត់ដូចមានចែងក្នុងកិច្ចសន្យា
- ប្រសិនបើភាគី "ខ" មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា
- ប្រសិនបើភាគី "ខ" ស្ថិតក្នុងស្ថានភាពក្ស័យធន ឬមិនអាចសងបំណុលបាន។

ក្នុងករណីដែល ភាគី "ក" បញ្ចប់កិច្ចសន្យាតាមចំណុចទី១ និងទី២ ខាងលើ ភាគី "ក" អាចធ្វើការងារដែលខកខានមិនបានប្រគល់ ប្រសិនបើខ្លួនគិតថាចាំបាច់ ហើយ ភាគី "ខ" ត្រូវទទួលខុសត្រូវចំពោះការចំណាយលើការងារដែលមិនបានប្រគល់នោះ។ ក្នុងករណីដែលបញ្ចប់កិច្ចសន្យាដោយហេតុផលក្ស័យធន ការលុបចោលកិច្ចសន្យានឹងមិនប៉ះពាល់ដល់សិទ្ធិ ឬសកម្មភាពណាមួយរបស់ ភាគី "ក" ឡើយ។ ការបញ្ចប់កិច្ចសន្យានេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៣- ការទូទាត់**

ការទូទាត់អាចធ្វើឡើងតែមួយលើក តាមលទ្ធផលប្រគល់-ទទួលជាក់ស្តែង ដោយមានកំណត់ហេតុប្រគល់-ទទួលច្បាស់លាស់។

រូបិយវត្ថុសម្រាប់ធ្វើការទូទាត់ គឺប្រាក់រៀល។ ការទូទាត់ត្រូវធ្វើឡើងតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយបង្វែរចូលគណនីរបស់ភាគី "ខ" លេខ: 0450000048688 នៅធនាគារ កាណាឌីយ៉ា ក.អ ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃ ក្រោយការប្រគល់-ទទួល។

**ប្រការ ១៤- ពន្ធ អាករ**

ភាគី "ខ" ត្រូវបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ នាពេលទូទាត់រហូតអស់តម្លៃកិច្ចសន្យា។

**ប្រការ ១៥- ការផាកពិន័យ**

- ក្នុងករណីភាគី "ខ" មិនបានប្រគល់នូវមុខទំនិញតាមពេលកំណត់នោះ ភាគី "ខ" ត្រូវទទួលរងនូវការផាកពិន័យជាប្រាក់ចំនួន ០,១០% ក្នុងមួយថ្ងៃ នៃតម្លៃទំនិញដែលប្រគល់យឺតយ៉ាវ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។ ចំនួនទឹកប្រាក់ពិន័យនេះ មិនត្រូវឱ្យលើសពី ១០%នៃតម្លៃកិច្ចសន្យាទេ ហើយនៅពេលដែលចំនួនទឹកប្រាក់ពិន័យលើសកម្រិតអតិបរមានេះ ភាគី "ក" អាចពិចារណាពីការលុបកិច្ចសន្យា។

- ក្នុងករណីដែលភាគី "ក" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ធ្វើការទូទាត់យឺតយ៉ាវនោះ ភាគី "ក" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូនភាគី "ខ" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។

**ប្រការ ១៦- ការទប់ទល់ នឹងលាភសក្ការៈ**

ភាគី "ខ" ត្រូវប្រកាសអះអាងថាខ្លួនមិនបានផ្តល់ ឬសន្យានឹងផ្តល់ប្រាក់ចំណាយ ឬលាភសក្ការៈណាមួយចំពោះមន្ត្រីនិយោជិតរដ្ឋាភិបាលណាមួយ ឬអ្នកដេញថ្លៃណាមួយដើម្បីទទួលបានកិច្ចសន្យា ហើយសកម្មភាពទាំងនេះ គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្អាក ឬលុបកិច្ចសន្យា។

**ប្រការ ១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "ក" និងភាគី "ខ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី ភាគី "ក" និងភាគី ភាគី "ខ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ

ហើយអាជ្ញាកណ្ដាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្ដាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១៨- សោហ៊ុយទាក់ទងរឿងក្ដី**

ក្នុងករណីរឿងក្ដីកើតឡើងដែលបណ្ដាលមកពីភាគី "ខ" រំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យា ភាគី "ខ" ត្រូវទទួលខុសត្រូវចំពោះភាគី "ក" រាល់ការចំណាយក្នុងការជួលមេធាវី។ ការចំណាយលើការខូចខាត និងចំណាយដទៃទៀតក្នុងរឿងក្ដីនោះ ត្រូវកំណត់ដោយច្បាប់។

**ប្រការ ១៩- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "ក" នោះភាគី "ខ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្ដល់ព័ត៌មានដែលមានចែងក្នុងកិច្ចសន្យាឱ្យអ្នកដទៃដឹងឡើយ លើកលែងតែប្រើប្រាស់ក្នុងបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

**ប្រការ ២០- ឋិសានវាទ**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់។ កិច្ចសន្យានេះត្រូវធ្វើជាភាសាខ្មែរចំនួនប្រាំបី(០៨) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

| | |
|---|---|
| - ភាគី "ក" | ចំនួន ០៣ ច្បាប់ |
| - ភាគី "ខ" | ចំនួន ០៣ ច្បាប់ |
| - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ០១ ច្បាប់ |
| - ឯកសារ-កាលប្បវត្តិ | ចំនួន ០១ ច្បាប់ |

ថ្ងៃ...ចន្ទ...១០កើត.........ខែ...ចេត្រ......ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....១១.........ខែ...មេសា......ឆ្នាំ ២០២២

**ភាគី "ក"**

ឈុន_គីមយាន

អនុប្រធាននាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ

**ភាគី "ខ"**

ក្រុមហ៊ុន មិនា អ៊ិនវេស្ទមិន

MINEA INVESTMENT Co., Ltd.

KINGDOM OF CAMBODIA

កែវ_សុមិនា

**បានឃើញ និង ឯកភាព**

ថ្ងៃ...ចន្ទ...១០កើត..........ខែ...ចេត្រ.........ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....១១........ខែ.....មេសា.........ឆ្នាំ ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ម៉ៅ_ហាចផ្កាល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ: ០០២/២២**

# កិច្ចសន្យា
## ស្តីពីការជួសជុលរថយន្ត និងត្រាក់ទ័រកាត់ស្មៅ
## ប្រចាំឆ្នាំ ២០២២

កិច្ចសន្យានេះធ្វើឡើងរវាង៖

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដោយ**លោក អៀន ខេមុន្នី** មុខងារ ប្រធានការិយាល័យគ្រឿងយន្ត នៃនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" ហៅកាត់ថា ភាគី "ក" មានអាសយដ្ឋានអគារលេខ: ៤៤, មហាវិថីសហព័ន្ធរុស្សី, ភូមិតាងួន, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ ទូរស័ព្ទលេខ: ០៧៧ ៥៥០ ០៧០ និង

-**ក្រុមហ៊ុន ធី វិទ្ធី ធី ហ្គាមិុន ឯ.ក** ត្រូវបានទទួលស្គាល់ថាជា "អ្នកទទួលការ" ហៅកាត់ថា ភាគី "ខ" តំណាងដោយ **លោក ធី វិទ្ធី** ជាប្រធានក្រុមហ៊ុន **ធី វិទ្ធី ធី ហ្គាមិុន ឯ.ក** មានអាសយដ្ឋានអគារលេខ: ១០៦, ផ្លូវលេខ: ១៨, សង្កាត់និរោធ, ខណ្ឌច្បារអំពៅ, រាជធានីភ្នំពេញ ទូរស័ព្ទលេខ: ០១២ ៧៣៤ ៤៤៥ អ៊ីមែល.................................................................................................................................។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោម ៖**

**ប្រការ ១- អំពីគោលការណ៍**

ភាគីទាំងពីរបានព្រមព្រៀងជួសជុលរថយន្ត និងត្រាក់ទ័រកាត់ស្មៅ ប្រចាំឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន: ១៥៧.៧២០.៧០០រៀល(មួយរយហាសិបប្រាំពីរលាន ប្រាំពីររយម្ភៃពាន់ប្រាំពីររយរៀលគត់)ជាតម្លៃកិច្ចសន្យា។

**ប្រការ ២- បរិយាយលក្ខណៈបច្ចេកទេស**

ភាគី "ខ" បានយល់ព្រមជួសជុលរថយន្ត និងត្រាក់ទ័រកាត់ស្មៅ ដែលមានបរិមាណ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានចែងក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេសជាឧបសម្ព័ន្ធកិច្ចសន្យា។

**ប្រការ ៣- ឯកសារឧបសម្ព័ន្ធរបស់កិច្ចសន្យា**

- លិខិតសម្រេចប្រគល់កិច្ចសន្យា
- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
- ប៉ាន់គំរូកាតាឡុក
- លក្ខខណ្ឌនៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត

**ប្រការ ៤- ការប្រគល់-ទទួល**

ភាគី "ខ" ត្រូវប្រគល់សម្ភារៈទាំងអស់ជូនភាគី "ក" តាមទីតាំងដែលបានកំណត់ យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន។ ការប្រគល់-ទទួល ត្រូវពិនិត្យឱ្យបានហ្មត់ចត់ត្រឹមត្រូវ

តាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស ប៉ាន់គំរូ កាតាឡុករបស់សម្ភារៈ ដូចមានចែងក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស។

ការប្រគល់-ទទួល អាចធ្វើឡើងជាដំណាក់កាលៗ តាមតម្រូវការចាំបាច់ ដោយមានកំណត់ហេតុប្រគល់-ទទួល ច្បាស់លាស់របស់គណៈកម្មការប្រគល់-ទទួល និងមានការយល់ព្រមពីប្រធានគណៈកម្មាធិការលទ្ធកម្ម និងត្រូវមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥- ការធានាគុណភាពទំនិញ**

ភាគី "ខ" ត្រូវធានាថា រាល់គុណភាពសម្ភារៈត្រូវឆ្លើយតបទៅនឹងប៉ាន់គំរូ កាតាឡុក និងធានាថាសម្ភារៈដែលត្រូវប្រគល់ ជាសម្ភារៈដែលមានលក្ខណៈបច្ចេកទេសស្របតាមលក្ខខណ្ឌដែលភាគី "ក" បានកំណត់។ ភាគី "ខ" យល់ព្រមផ្លាស់ប្តូរជំនួស ឬកែតម្រូវដោយចំណាយផ្ទាល់ខ្លួន ចំពោះមុខសម្ភារៈដែលខូចខាត ឬផ្នែកណាមួយនៃសម្ភារៈ ក្រោយពីភាគី "ក" បានប្រាប់ឱ្យដឹងអំពីលក្ខណៈនៃការខូចខាតនោះ។ ប្រសិនបើភាគី "ខ" ខកខានមិនបានសងការខូចខាត ឬជំនួសទេនោះ ភាគី "ក" អាចចាត់វិធានការចាំបាច់ទិញពីអ្នកផ្សេងទៀត ដែលការចំណាយជាបន្ទុករបស់ភាគី "ខ" ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិណាមួយរបស់ភាគី "ក" ដែលមាននៅក្នុងកិច្ចសន្យា។ ករណីមានការធានាលើសេវាប្រើប្រាស់ ត្រូវចែងឱ្យបានច្បាស់ក្នុងកិច្ចសន្យា។

**ប្រការ ៦- ប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា**

